CITY OF LONGBEACH PRESS RELEASE

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី ១២ ខែឧសភាឆ្នាំ ២០២០
ទំនាក់ទំនង៖ មជ្ឈមណ្ឌលព័ត៌មានរួមនៃទីក្រុងឡុងប៊ិច 562.570.NEWS(6397) jic@longbeach.gov

សម្រាប់សេចក្តីប្រកាសជាបន្ទាន់

# របាំងមុខគឺជាតម្រូវការចាំបាច់នៅអាកាសយានដ្ឋានឡុងប៊ិច

ទីក្រុងឡុងប៊ិចរដ្ឋកាលីហ្វ័រញ៉ា – ជាផ្នែកមួយនៃការប្រុងប្រយ័ត្នខាងសុវត្ថិភាពដែលកំពុងបន្តអនុវត្ត អាកាសយានដ្ឋានឡុងប៊ិច (LGB) តម្រូវឱ្យអ្នកដំណើរ និយោជិក និងអ្នកទស្សនាទាំងអស់ពាក់ របាំងមុខពេលកំពុងនៅលើអាកាសយានដ្ឋាន។ គោលនយោបាយនេះគឺអនុលោមតាមបទបញ្ជា "រក្សាសុវត្ថិភាពដោយនៅផ្ទះ" បច្ចុប្បន្នរបស់ទីក្រុងឡុងប៊ិចនិងការណែនាំពីអ្នកជំនាញសុខភាពសាធារណៈ។

លោកអភិបាលក្រុង Robert Garcia មានប្រសាសន៍ថា "នៅពេលសេដ្ឋកិច្ចបើកដំណើរការឡើងវិញបន្តិចម្តងៗ ហើយប្រជាជនចាប់ផ្តើមធ្វើដំណើរឡើងវិញយើងចង់ធានានូវបទពិសោធន៍ដែលប្រកបដោយសុវត្ថិភាពបំផុតសម្រាប់អ្នកដំណើរទាំងអស់។"

មជ្ឈមណ្ឌលត្រួតពិនិត្យនិងបង្ការជំងឺ (Center for Disease Control) ណែនាំឱ្យពាក់ស្បៃឬរបាំងមុខដែលគ្របច្រមុះនិងមាត់នៅពេលចេញទៅក្រៅជាសាធារណៈដើម្បីការពារការរាលដាលនៃជំងឺកូវីដ-១៩។ ឧទាហរណ៍នៃឧបករណ៍បិទបាំងមុខដែលសមរម្យរួមមាន កន្សែងដៃធំ កន្សែងរុំក ឬរបាំងក្រណាត់ដែលមានចំណងឬខ្សែ។ គឺជាការសំខាន់ក្នុងការកត់សម្គាល់ថាការបិទបាំងមុខមិនមែនអាចជំនួសការរក្សាចម្ងាយរាងកាយពីគ្នានិងការលាងដៃជាញឹកញាប់នោះទេ។

លោកស្រី Cynthia Guidry នាយកអាកាសយានដ្ឋានឡុងប៊ិចបានមានប្រសាសន៍ថា "ដៃគូរបស់យើងនៅអាកាសយានដ្ឋានឡុងប៊ិចបានរួមគ្នាផ្តល់នូវបរិស្ថានប្រកបដោយសុវត្ថិភាពព្រមទាំងរក្សាបាននូវបទពិសោធន៍ដ៏សុខស្រួលដែលអតិថិជនបានរំពឹងទុក។ "យើងទន្ទឹងរងចាំទទួលអ្នកដំណើរបន្ថែមទៀតប៉ុន្តែយើងសូមថ្លែងអំណរគុណដល់សាធារណជនដែលយកចិត្តទុកដាក់លើបទបញ្ជាសុខភាពនិងជៀសវាងការធ្វើដំណើរដែលមិនចាំបាច់។ អាកាសយានដ្ឋានឡុងប៊ិចត្រៀមស្វាគមន៍ការវិលត្រឡប់មកវិញរបស់លោកអ្នក។"

ក្រុមហ៊ុនអាកាសចរណ៍ទាំង ៥ ដែលបម្រើការនៅអាកាសយានដ្ឋានឡុងប៊ិចក៏ដូចជាស្តង់សម្រាប់លក់អាហារសម្រន់និងក្រុមហ៊ុនជួលរថយន្តឥឡូវនេះតម្រូវឱ្យមានការបិទបាំងមុខទាំងអតិថិជននិងនិយោជិក។ មន្ត្រីក្រសួងរដ្ឋបាលសន្តិសុខធ្វើដំណើរ (Transportation Security Administration) នៅអាកាសយានដ្ឋានឡុងប៊ិចក៏ត្រូវពាក់ម៉ាស់ផងដែរ។ មន្ត្រីអាចស្នើសុំឱ្យភ្ញៀវកែសំរួលឬបើកគម្របមុខបណ្តោះអាសន្នក្នុងកំឡុងពេលដំណើរការត្រួតពិនិត្យសន្តិសុខ។

បន្ថែមពីលើតម្រូវការគ្របមុខអាកាសយានដ្ឋានឡុងប៊ិចបានដាក់ចេញនូវវិធានការណ៍សុវត្ថិភាពបន្ថែមមួយចំនួនដូចជាពិធីសារអនាម័យថ្មីៗនិងកំនោះសម្គាល់នៅលើឥដ្ឋដើម្បីរក្សាចម្ងាយរាងកាយពីគ្នា។

សម្រាប់ព័ត៌មានថ្មីៗអំពីជំងឺកូវីដ-១៩រួមទាំងព័ត៌មានលម្អិតអំពីអ្វីដែលទីក្រុងឡុងប៊ិចកំពុងអនុវត្តដើម្បីការពារសុវត្ថិភាពដល់ប្រជាជនសូមមេត្តាចូលទៅកាន់គេហទំព័រ longbeach.gov/COVID19 ហើយតាមដាន @LongBeachCity នៅលើប្រពន្ធ័ហ្វេសប៊ុក ធ្វីតធ័រ និង Instagram។

# # #